លេខ / N°: D384

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| ឯកសារដើម |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 06 / 2019 |
| ម៉ោង (Time/Heure): 11:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA |

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

# ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ផ្ញើជូន:

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដី យឹម ទិត្យ**
ស្វ មូស្សេទ្ធី
Suzana TOMANOVIĆ

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

## I. **ប្រវត្តិនីតិវិធី**

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿង ០០៤ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ និងថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៩។

២. ចាប់តាំងពីបើកកិច្ចស៊ើបសួរសំណុំរឿង ០០៤ មក មានមនុស្សចំនួន ២០១៤ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ស.ច.ស បានប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill និង សេង ចាន់ធារី មិនអាចទទួលយកបានឡើយ[1]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានប្តឹងជំទាស់ទៅនឹងដីកាសម្រេចរបស់ ស.ច.ស[2]។

៤. នៅថ្ងៃទី ១៤ និង ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គបុរេជំនុំជម្រះ("អ.ប.ជ") មិនអាចរកសម្លេងភាគច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចសេចក្តីលើបណ្តឹងជំទាស់របស់អ្នកដាក់ពាក្យសុំទាំងពីរបានឡើយ[3]។

---

[1] សំណុំរឿង០០៤-D5/1/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ សំណុំរឿង០០៤-D5/2/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[2] សំណុំរឿង០០៤-D5/1/4/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សំណុំរឿង ០០៤-D5/2/4/2 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill* ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១។

[3] សំណុំរឿង០០៤-D5/2/4/3 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamill* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណុំរឿង០០៤-D5/1/4/2 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សេង ចាន់ធារី* ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

៥. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ សេង ចាន់ធារី បានដកពាក្យសុំរបស់គាត់ចេញពីសំណុំរឿង ០០៤[4]។ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស") បានទទួលស្គាល់ការដកពាក្យសុំនេះ តាមរយៈលិខិតចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤[5]។

៦. នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ Robert Hamill បានស្នើសុំឱ្យ ស.ច.ស ពិចារណាឡើងវិញលើដីកាសម្រេចអំពីភាពអាចទទួលស្គាល់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី[6]។ ស.ច.ស មិនបានចេញដីកាសម្រេចថ្មីលើភាពអាចទទួលស្គាល់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីទេ។ នៅក្នុងដីកាសម្រេចនេះ យើង Michael Bohlander សម្រេចលើភាពអាចទទួលស្គាល់ Robert Hamill ជាដើមបណ្ដឹងរដ្ឋប្បវេណី។

៧. នៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស អន្តរជាតិបម្រុង បានផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដល់អ្នកដាក់ពាក្យសុំចំនួន ៣០ នាក់[7]។ នៅក្នុងដីកាសម្រេចនេះ យើង

---

[4] សំណុំរឿង០០៤-**D5/1/5** *សំណើសុំដកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 11-VSS-00001 របស់ សេង ចាន់ធារី* ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤។

[5] សំណុំរឿង០០៤-**D5/1/6** *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី ជួង ជូងី* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៤-**D5/1/7** *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី សំ សុគង់* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៤-**D5/1/8** *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី Emmanuel Jacomy* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។

[6] សំណុំរឿង ០០៤-**D5/2/5** *សំណើសុំសហចៅក្រមស៊ើបអង្កេត ពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ROBERT Hamill (D11/2/3)* ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១។

[7] សំណុំរឿង ០០៤-**D5/40/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ចឹង ភី* ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/45/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ង៉ែត ចាត* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/55/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈឹម ស្រ៊ន* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/60/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ង៉ែត វុត* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/61/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជឿក យឿន* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/62/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ វ៉ាន់ ធូក* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/66/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ចិច សុផា* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/72/3** *ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*

របស់ គី សឹង ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/75/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គីម ផេង ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/76/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សម ស័ក្ត ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/87/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ៅ ថេង ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/89/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ផាន់ សារ៉ាយ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/97/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ប៊ុច ឆេវ ហៅ តាំង សេវ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/98/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឃៀម ប៉ូ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/110/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់វ៉ើន ថែន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/113/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ទិត សុផារី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/114/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្នូង តឿ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/119/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ៊ុន សុវណ្ណារី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/147/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គីម សួរ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/155/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម៉ី សំ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/180/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម៉ិច ម៉ន់ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/182/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ទៀម កយ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/187/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ហែម សារឿន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/197/4** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម៉ី សារឿន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/203/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ទូច ហ៊ី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/205/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខៀវ ខាន់ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/239/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សារួន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/240/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កែន ជូ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/241/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុំ សុផុន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។ សំណុំរឿង០០៤-**D5/314/3** ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខូយ សារុន ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២។

Michael Bohlander នឹងវាយតម្លៃឡើងវិញ ហើយប្រសិនបើចាំបាច់ នឹងពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ ស.ច.ស អន្តរជាតិបម្រុង យោងលើការវិវត្តនៃកិច្ចស៊ើបសួរ។

៨. នៅក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និង សំណុំរឿង ០០៤/២ ក.ស.ច.ស ត្រូវបានជូនដំណឹងឲ្យដឹងថា អ្នកដាក់ពាក្យសុំចំនួន ៤៧ នាក់នៅក្នុងសំណុំរឿង ០០៤ បានទទួលមរណភាព[8]។ សិទ្ធិវន្តរបស់អ្នកដាក់ពាក្យសុំម្នាក់ដែលទទួលមរណភាព បានបង្ហាញឆន្ទៈចង់ក្លាយជាអ្នកបន្តបណ្តឹងជំនួសអ្នកស្លាប់[9]។ អ្នកដាក់ពាក្យសុំចំនួន បី នាក់ បានដកពាក្យវិញ[10]។

៩. នៅក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និង សំណុំរឿង ០០៤/២ ក.ស.ច.ស បានស្តាប់ចម្លើយអ្នកដាក់ពាក្យសុំមួយចំនួននៅក្នុងសំណុំរឿង ០០៤ ចំណែកឯនៅក្នុងសំណុំរឿង ០០២, ០០២/១ និង ០០២/២ អង្គជំនុំជម្រះសាលាដំបូង("អ.ជ.ស.ដ")បានស្តាប់សក្ខីកម្មអ្នកដាក់ពាក្យសុំពីសំណុំរឿង០០៤។ កំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស និងប្រតិចារឹកសវនាការរបស់ អ.ជ.ស.ដ នឹងមានបង្ហាញនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។

---

[8] ឧបសម្ព័ន ឃ *អនុស្សរណៈពីអង្គភាពគាំពារជនរងគ្រោះផ្ញើជូន ក.ស.ច.ស* ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៨។ ឧបសម្ព័ន្ធ ង *អង្គភាពគាំពារជនរងគ្រោះ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព* ។ សំណុំរឿង ០០៤-D353.2 *ឧបសម្ព័ន្ធ ២* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤-D219/856 *របាយការណ៍នៃសកម្មភាពស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤/១-D307 *ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៧។

[9] សំណុំរឿង ០០៤-D5/641/3 *លិខិតពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំពី "សិទ្ធិវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាពដើម្បីបន្តការទាមទារសំណងរដ្ឋប្បវេណី ឯកសារលេខ D5/641"* ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៦។

[10] សំណុំរឿង ០០៤-D5/1114/3 *លិខិតផ្ញើជូនមេធាវី* ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤-D5/1921/3 *លិខិតផ្ញើជូនមេធាវី អំពីការដកលោក ឌី ដានី ចេញពីសំណុំរឿង ០០៣, ០០៤ និង ០០៤/២* ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៨។ សំណុំរឿង ០០៤/១-D307 *ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៧។

១០. នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៧ និងថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០១៧ យើង Michael Bohlander បានបង្គាប់ឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤ ត្រូវមានអ្នកតំណាងផ្នែកច្បាប់[11] ហើយលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិបន្ថែមទៀតបានដាក់ចូលក្នុងសំណុំរឿងរួចហើយចាប់តាំងពីពេលនោះមក។ ហេតុនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មានអ្នកតំណាងផ្លូវច្បាប់ហើយ។

១១. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ យើង Michael Bohlander បានបដិសេធសំណើទាំងអស់របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ ដែលស្នើសុំវិធានការការពារ[12]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានស្នើសុំវិធានការការពារ ("អ្នកដាក់ពាក្យសុំដែលស្នើសុំវិធានការការពារ")[13]។ នៅក្នុងដីកាសម្រេចនេះ យើងMichael Bohlander នឹងធ្វើសេចក្តីសម្រេចលើសំណើនេះ។

## II. ពិភាក្សា

### ក) សេចក្តីផ្តើម

១២. នៅក្នុងដីកាសម្រេចនេះ យើង Michael Bohlander បង្ហាញគោលការណ៍ច្បាប់ និងលក្ខណៈវិនិច្ឆ័យដែលយើងយកមកប្រើដើម្បីសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤។ នៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងដីកា

---

[11]សំណុំរឿង ០០៤-**D330** *ដីកាសម្រេចចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់* ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤-**D343** *ដីកាសម្រេចទទួលស្គាល់មេធាវី និងការចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤-**D352** *ដីកាសម្រេចចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផ្សេងទៀត* ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៧។

[12]សំណុំរឿង ០០៤-**D353** *ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧។

[13] សំណុំរឿង ០០៤-**D5/2008** *ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុន ឈីវហុង* ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដាក់នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១។

សម្រេចនេះ យើង Michael Bohlander បង្ហាញសេចក្តីសន្និដ្ឋានយើង អំពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំនីមួយៗ ដោយផ្តល់សំអាងហេតុ ចំពោះករណីដែលទទួលស្គាល់ និងករណីដែលមិនទទួលស្គាល់។

**ខ) គោលការណ៍ណែនាំ**

១៣. ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញអត្តសញ្ញាណឱ្យបានច្បាស់លាស់ និងត្រូវបង្ហាញថា ដោយសារលទ្ធផលផ្ទាល់ពីឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទលើជនត្រូវចោទ អ្នកដាក់ពាក្យសុំពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព[14]។ ភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺអាស្រ័យលើការវាយតម្លៃលើកាលៈទេសៈផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំ ពាក់ព័ន្ធនឹងការចោទប្រកាន់ ដោយទទួលយកការចោទប្រកាន់ទាំងនោះតាមលក្ខណៈជាក់ស្តែង[15]។

១៤. វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ចែងពីគោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី។ អនុលោមតាមច្បាប់ អ.វ.ត.ក[16] ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬការអនុវត្តគោលការណ៍ជាមូលដ្ឋានទាំងនេះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ រួមមាន៖

ក) យុត្តិសាស្ត្រពីតុលាការ និងសាលាក្តីសិទ្ធិមនុស្សថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ដែលជាប់ពាក់ព័ន្ធ

---

[14]អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ("វិធានផ្ទៃក្នុង") វិធានផ្ទៃក្នុង ២៣ *ស្ទួន*(១)។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (វិសោធនកម្មលើក ទី ១) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ មាត្រា ៣.២។

[15] *សូមមើលខាងលើ*។

[16]ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤(នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី។

ខ) មាត្រា ១, ២, ៤ និង ១៨ នៃមហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការរំលោភអំណាច[17]។

១៥. អង្គជំនុំជម្រះតុលាការកំពូល("អ.ជ.ត.ក") បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា តុលាការសិទ្ធិមនុស្សថ្នាក់តំបន់ គឺផ្តោតលើ "*ការទទួលខុសត្រូវរបស់រដ្ឋ*" មិនមែនលើ"*ការទទួលខុសត្រូវជាលក្ខណៈបុគ្គល*"ទេ។ ហេតុនេះ យើង Michael Bohlander ប្រកាន់យកវិធីសាស្ត្រមួយដ៏ប្រយ័ត្នប្រយែង ក្នុងការអនុវត្តយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ ដើម្បីសម្រេចសេចក្តីលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយទទួលស្គាល់ថា ជាគោលការណ៍ តុលាការទាំងនេះ"*មានគោលការណ៍ផ្សេងពី អ.វ.ត.ក*"[18]។

១៦. ដោយសារថា វិធានផ្ទៃក្នុង ២៣ *ស្ទួន*(១) និង មាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មានខ្លឹមសារស្របគ្នានឹងមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ហើយក្រមនេះបានបង្កើតឡើងដោយសារ និងដូចគ្នាយ៉ាងខ្លាំងជាមួយនឹងមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ទើបជាការល្អផងដែរគឺគួរពិនិត្យមើលគោលការណ៍ទូទៅស្តីពីជនរងគ្រោះ ដែលមានចែងក្នុងច្បាប់បារាំង។

---

[17] *សេចក្តីប្រកាសស្តីពីសិទ្ធិជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃការរំលោភអំណាច* សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៤០/៣៤ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ (A/RES/40/34)។

[18] សំណុំរឿង ០០១-F28 *សាលដីកាសំណុំរឿង ០០១* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សាលដីកាសំណុំរឿង ០០១") កថាខណ្ឌ ៤៣១។

## គ) ប្រភេទជនរងគ្រោះ និងភាពអាចទទួលស្គាល់ជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណី

### i. <u>ជនរងគ្រោះផ្ទាល់</u>

១៧. ជនរងគ្រោះផ្ទាល់ (ជួនកាលហៅថា ជនរងគ្រោះ *"ដោយផ្ទាល់-immediate"* ឬជនរងគ្រោះ"ដំបូង")[19] សំដៅលើ *"ក្រុមបុគ្គលណាដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬទទួលរងការប៉ះពាល់ដែលបណ្ដាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់"*[20]។

១៨. ក្នុងករណីមរណភាពរបស់ជនរងគ្រោះផ្ទាល់ សិទ្ធិវ័ន្តរបស់គាត់អាចដាក់បណ្ដឹងរដ្ឋប្បវេណីបន្តជំនួសគាត់[21]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា ក្នុងករណីមរណភាពរបស់ជនរងគ្រោះ បណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានផ្ដើមធ្វើ ឬ បន្តដោយសិទ្ធិវ័ន្ត[22]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា សិទ្ធិវ័ន្តអាចជំនួសអ្នកស្លាប់បាន តែក្នុងករណីដែលអ្នកស្លាប់នោះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយតែប៉ុណ្ណោះ[23] ប៉ុន្តែ ការ

---

[19] **សំណុំរឿង ០០១-E188** *សាលក្រម* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមសំណុំរឿង ០០១") កថាខណ្ឌ ៦៤៣-៦៤៤, ៦៤៨-៦៥០, ៦៦៧។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Joseph Kony, Vincent Otti, Okot Odhiambo, Dominic Ongwen* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីប្រឆាំងនឹងសេចក្ដីសម្រេចដែលមានចំណងជើងថា "ដីកាសម្រេចស្ដីពីពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 to a/0070/06, a/0081/06, a/0082/06, a/0084/06 to a/0089/06, a/0091/06 to a/0097/06, a/0099/06, a/0100/06, a/0102/06 to a/0104/06, a/0111/06, a/0113/06 to a/0117/06, a/0120/06, a/0121/06 និង a/0123/06 ដល់ a/0127/06" របស់អង្គបុរេជំនុំជម្រះ II តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (ICC-02/04-179) ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សេចក្ដីសម្រេចរឿងក្ដី *Kony*") កថាខណ្ឌ ២៩។

[20] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៦។

[21] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤២១។ សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ៦៤១។ **សំណុំរឿង ០០១-E2/5/3** *សេចក្ដីសម្រេចលើពាក្យសុំទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលមរណភាព ("សេចក្ដីសម្រេចពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលមរណភាព")* ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១០-១២។ *សូមមើលផងដែរ៖* គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ(UNHRC) រឿងក្ដី *Guerra និង Wallen តទល់នឹង Trinidad និង Tobago* លេខ 576/94 និង 576/94 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៦.២។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៦។

[23] សេចក្ដីសម្រេចពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលមរណភាព កថាខណ្ឌ ១១-១២។

សម្រេចបែបនេះផ្ទុយគ្នាជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយ អ.ជ.ត.ក ចាត់ទុកការកំហិតនេះ ថាពុំមានមូលដ្ឋាននៅក្នុងច្បាប់ជាធរមានឡើយ[24]។

១៩. ដូច្នេះ នៅពេលដែលជនរងគ្រោះផ្ទាល់ទទួលមរណភាព សិទ្ធិវន្តអាចចូលរួមតាមពីររបៀប គឺ គាត់អាចចូលរួមជំនួសអ្នកស្លាប់ ឬក៏ចូលរួមក្នុងនាមខ្លួនឯងផ្ទាល់ ជាជនរងគ្រោះមិនផ្ទាល់ចំពោះព្យសនកម្មដែលសិទ្ធិវន្តបានទទួលរងដោយសារផលលំបាកពីព្យសនកម្មរបស់ជនរងគ្រោះផ្ទាល់[25]។ ទោះបីជាចូលរួមតាមរបៀបមួយណាក៏ដោយ ក៏អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ថាតើគាត់ដាក់ពាក្យសុំក្នុងនាមជាសិទ្ធិវន្តជំនួសជនរងគ្រោះផ្ទាល់ ឬក៏ក្នុងនាមជនរងគ្រោះមិនផ្ទាល់។

ii. <u>ជនរងគ្រោះមិនផ្ទាល់</u>

២០. ក្រៅពីជនរងគ្រោះផ្ទាល់ អ្នក *"ដែលទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើជនរងគ្រោះផ្ទាល់"* ក៏អាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជាជនរងគ្រោះមិនផ្ទាល់បានដែរ[26]។ អ.ជ.ត.ក បានសម្រេចថា *"ការអនុវត្តសិទ្ធិក្នុងនាមជាជនរងគ្រោះមិនផ្ទាល់ គឺមានលក្ខណៈឯករាជ្យពីសិទ្ធិរបស់ជនរងគ្រោះផ្ទាល់"*[27]។ ដូច្នេះ ជនរងគ្រោះមិនផ្ទាល់អាចទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីទោះបីជាជនរងគ្រោះផ្ទាល់មិនបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ[28]។

---

[24] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤២១។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានគាំទ្រដោយច្បាប់បារាំង៖ ប្រទេសបារាំង Cour de cassation, Assemblée plénière ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ លេខ 06-85.751 និង 05-87.379: « *Le droit à réparation du préjudice éprouvé par la victime avant son décès, étant né dans son patrimoine, se transmet à ses héritiers.* »

[25] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៩។

[26] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៨។

[27] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៨។

[28] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៨។

iii. <u>ភាពខុសគ្នារវាងជនរងគ្រោះដែលជាអ្នកប្រព្រឹត្តបទល្មើស</u>

២១. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនដែលបានចូលរួមចំណែកប្រព្រឹត្តបទល្មើសដែលជននោះអះអាងថាខ្លួនឯងជាជនរងគ្រោះនៃបទល្មើសនោះ នឹងត្រូវសម្រេចថាមិនអាចទទួលយកឡើយ។ មានការទទួលស្គាល់ថា អ្នកប្រព្រឹត្តបទល្មើស អាចទទួលរងព្យសនកម្មផ្លូវចិត្តដោយសារខ្លួនឯងបានចូលរួមបទល្មើសអន្តរជាតិ[29] ប៉ុន្តែ ជនបែបនេះមិនអាចត្រូវអនុញ្ញាតឲ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងអ្នកប្រព្រឹត្តផ្សេងទៀតដែលត្រូវបានចោទអំពីបទល្មើសដូចគ្នានេះឡើយ[30]។ ជាពិសេស ក្នុងករណីដែលកាលៈទេសៈនៃការប្រព្រឹត្តិបទល្មើសមិន "*ហួសពីការគ្រប់គ្រង[របស់អ្នកប្រព្រឹត្តដែលជាជនរងគ្រោះ]*"។[31]

## ឃ) ប្រភេទព្យសនកម្ម

២២. ដើម្បីអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន អ្នកដាក់ពាក្យសុំ ត្រូវតែបានទទួលរងព្យសនកម្មពិតប្រាកដមែន[32]។

---

[29] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Thomas Lubanga Dyilo* សាលក្រមលើការដាក់ទោស យោងតាមមាត្រា៧៦ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូង តុលាការ ICC (ICC-01/04-01/06-2901) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៣៩ និងកថាខណ្ឌបន្ទាប់ នៅក្នុងបរិបទពិសេសអំពីទាហានកុមារ។

[30] ប្រទេសបារាំង Cour de cassation, Chambre criminelle ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ លេខ 96-85.880 និង ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០១ លេខ 00-83.023។

[31] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Dominic Ongwen* សេចក្តីសម្រេចអំពីការបញ្ជាក់បទចោទលើ Dominic Ongwen អង្គបុរេជំនុំជម្រះ តុលាការ ICC (ICC-02/04-01/15-422-Red) ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ១៥៤។

[32] វិធានផ្ទៃក្នុង ២៣ ស្ទួន(១)(ខ)។ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(ខ) (ii)។ ពាក្យថា "*ព្យសនកម្ម*" និង "*ការខូចខាត*" ត្រូវបានចាត់ទុកថាអាចប្រើជំនួសគ្នាបាន ហើយមិនមានភាពខុសគ្នាផ្នែកច្បាប់នៅក្នុងបរិបទនេះឡើយ។ សំណៅភាសាបារាំងនៃវិធានផ្ទៃក្នុង ប្រើតែពាក្យមួយនៅក្នុងឯកសារទាំងមូល។ សំណៅជាភាសាខ្មែរ ប្រើពាក្យពីរខុសគ្នា ប៉ុន្តែអាចប្រើជំនួសគ្នាបានគឺពាក្យ ("ព្យសនកម្ម" និង "ខូចខាត")៖ **សំណុំរឿង ០០២-D404/2/4** *សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២") កថាខណ្ឌ ៤៤-៤៩។ សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៥។

២៣. វិធាន ២៣ ស្ទួន(១)(ខ) ចែងថា ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មនោះត្រូវតែជា (i) ព្យសនកម្មខាងរូបរាងកាយ (ii) ព្យសនកម្មខាងសម្ភារៈ ឬ (iii) ព្យសនកម្មខាងផ្លូវចិត្ត។

i. ព្យសនកម្មខាងរូបរាងកាយ

២៤. យោងតាម អ.ជ.ត.ក ព្យសនកម្មខាងរូបរាងកាយ “*មានន័យថាការខូចខាតខាងជីវសាស្ត្រខាងសរីរាង្គ ឬ ខាងប្រព័ន្ធដំណើរការនៃសរីរាង្គ។ វាអាចរបួសស្នាម កាយវិកលកម្ម ការខូចទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬ ការមិនដំណើរការនៃសរីរាង្គណាមួយ ឬ មរណភាព*”[33]។

២៥. ចៅក្រមនៅអង្គបុរេជំនុំជម្រះនៃសាលាក្តីពិសេសសម្រាប់លីបង់ ចាត់ទុកព្យសនកម្មផ្នែករាងកាយថា“*ពាក់ព័ន្ធនឹងរូបរាងកាយ*” ហើយ “*តាមធម្មតា តម្រូវឱ្យមានការព្យាបាលកម្រិតណាមួយសម្រាប់ជនរងគ្រោះ*”[34]។ អ.ជ.ត.ក បានគូសបញ្ជាក់បន្ថែមថា ព្យសនកម្មផ្នែករាងកាយអាចទទួលរងដោយ“*អ្នកដែលងាយរងគ្រោះ ដូចជា ទារក កុមារ មនុស្សចាស់ និង អ្នកជំងឺ ដោយសារតែការបាត់បង់អ្នកបីបាច់ថែរក្សារបស់ខ្លួន*”[35]។ ព្យសនកម្មនេះក៏អាចកើតមកពីព្យសនកម្មផ្លូវចិត្តរយៈពេលយូរ ដែលបណ្តាលឱ្យមានជំងឺជង្កាត់ផ្សេងៗ[36]។

ii. ព្យសនកម្មខាងសម្ភារៈ

២៦. អ.ជ.ត.ក យល់ឃើញថា ព្យសនកម្មខាងសម្ភារៈ“*សំដៅលើការបាត់តម្លៃជាវត្ថុបិយ ដូចជា ការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬ មួយផ្នែក ឬ ការបាត់បង់ប្រាក់*

[33] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៥។

[34] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Salim Jamil Ayyash, Mustafa Amine Badreddine, Hussein Hassan Oneissi & Assad Hassan Sabra* សេចក្តីសម្រេចស្តីពីការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី អង្គបុរេជំនុំជម្រះនៃសាលាក្តីពិសេសសម្រាប់លីបង់ (STL-11-01/PT/PTJ) ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៦៤, ៦៦។

[35] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៧។

[36] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៨៦។

*ចំណូលជាដើម*"[37]។ ព្យសនកម្មខាងសម្ភារៈ ត្រូវបានកំណត់និយមន័យថា ជាការបាត់បង់សម្ភារៈ ប៉ុន្តែ អ.ជ.ត.ក និង អ.ប.ជ ក៏បានពិចារណាផងដែរទៅលើផលប៉ះពាល់ដែលគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា មានមកលើក្រុមគ្រួសារ ព្រមទាំងរបៀបផ្គត់ផ្គង់ និងថែទាំមនុស្សចាស់ សមាជិកគ្រួសារដែលងាយរងគ្រោះ និងសមាជិកដែលងាយរងគ្រោះនៅក្នុងសហគមន៍[38]។

២៧. ជាពិសេស អ.ជ.ត.ក បានសម្រេចថា ព្យសនកម្មប្រភេទនេះអាចកើតមានដោយសារពេលដែល"*ជនរងគ្រោះដោយផ្ទាល់បានផ្ទេរទៅឱ្យ[ជនរងគ្រោះមិនផ្ទាល់] នៅពេលមួយ [...] ឬ នឹងអាចផ្ទេរទៅឱ្យនាពេលអនាគត*"[39]។ ឧទាហរណ៍ ករណីទំនាក់ទំនងរវាងឪពុកម្តាយ ជាមួយនឹងកូន[40]។ ដូច្នេះ ទាំងជនរងគ្រោះផ្ទាល់ ទាំងជនរងគ្រោះមិនផ្ទាល់ សុទ្ធតែអាចរងព្យសនកម្មខាងសម្ភារៈ។

iii. <u>ព្យសនកម្មខាងផ្លូវចិត្ត</u>

២៨. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់នៅក្នុងសំណុំរឿង 00៤ អះអាងថា ពួកគាត់ទទួលរងព្យសនកម្មខាងផ្លូវចិត្ត ក្នុងនាមជាជនរងគ្រោះទាំងផ្ទាល់ ទាំងមិនផ្ទាល់។

២៩. ព្យសនកម្មខាងផ្លូវចិត្ត កើតឡើងដោយជំងឺធ្លាក់ទឹកចិត្ត វិបល្លាសផ្លូវចិត្ត ឬ ជំងឺផ្លូវចិត្ត រួមទាំងជំងឺបាក់ស្បាត[41]។ វាក៏អាចបណ្តាលមកពីការគ្រាន់តែបានមើលឃើញហេតុការណ៍

---

[37] សាលដីកាសំណុំរឿង 00១ កថាខណ្ឌ ៩១៥។

[38] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង 00២ កថាខណ្ឌ ៨៦។ សាលដីកាសំណុំរឿង 00១ កថាខណ្ឌ ៩១៧។

[39] សាលដីកាសំណុំរឿង 00១ កថាខណ្ឌ ៩១៧។

[40] សាលដីកាសំណុំរឿង 00១ កថាខណ្ឌ ៩១៧។

[41] សាលដីកាសំណុំរឿង 00១ កថាខណ្ឌ ៩១៥។

រន្ធត់ ឬ ព្រឹត្តិការណ៍ហិង្សាដោយផ្ទាល់ភ្នែក[42] ឬ មានអារម្មណ៍ពិបាកក្នុងចិត្តពេលរំឭក ហេតុការណ៍នោះឡើងវិញ មិនថារឿងនោះកើតឡើង ៣០ ឆ្នាំកន្លងទៅហើយក៏ដោយ[43]។

៣០. ចំពោះជនរងគ្រោះមិនផ្ទាល់ ព្យសនកម្មខាងផ្លូវចិត្ត អាចបណ្តាលមកពីបងប្អូនស្លាប់ ឬ ភាពពុំប្រាកដប្រជា និង ភាពភ័យខ្លាចអំពីជោគវាសនារបស់ជនរងគ្រោះផ្ទាល់ ឬ ការដឹងអំពីការឈឺចាប់របស់ជនរងគ្រោះទាំងនោះ ឬ ការមានអារម្មណ៍ភ័យខ្លាចអំពីសុវត្ថិភាព និងគ្មានសុចរិតភាព[44]។

៣១. ត្រង់ចំណុចនេះ លក្ខណៈវិនិច្ឆ័យនៃ“*ចំណងពិសេសនៃក្តីស្រលាញ់ ឬការរស់នៅក្នុងបន្ទុក*” សម្រាប់ជនរងគ្រោះផ្ទាល់ គឺមានភាពពាក់ព័ន្ធនឹងការសម្រេចសេចក្តីលើអត្ថិភាពនៃព្យសនកម្មខាងផ្លូវចិត្ត[45] ហើយ ព្យសនកម្មខាងផ្លូវចិត្តអាចបណ្តាលមកពីព្យសនកម្មដែលទទួលរងដោយសាច់ញាតិឆ្ងាយ ឬគ្រាន់តែជាមិត្តភក្តិ[46]។

៣២. អ.ប.ជ ថែមទាំងសម្រេចថា ព្យសនកម្មខាងផ្លូវចិត្តអាចបណ្តាលមកពីព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងមនុស្សមកពីសហគមន៍ជាមួយគ្នា ដែលរស់នៅដោយពឹងពាក់គ្នាទៅវិញទៅមក[47]។ អ.ប.ជ បានសម្រេចថា ព្យសនកម្មគួរអាចវាស់វែងបាន ក្នុងបរិបទនៃព្យសនកម្ម

---

[42]ស្ថានការណ៍ក្នុងប្រទេសអ៊ុយហ្គាន់ដា *សេចក្តីសម្រេចស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងបណ្តឹងឧទ្ធរណ៍* (“សេចក្តីសម្រេចស្តីពីការចូលរួមរបស់ជនរងគ្រោះអ៊ុយហ្គាន់ដា”) អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC, (ICC-02/04-164) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១០។

[43] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៨៥។

[44] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(គ)។ សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៧។

[45] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤៤៦-៤៤៧។

[46] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៨។

[47] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៨៦, ៨៨, ៩១។ ការសម្រេចនេះស្របតាមយុត្តិសាស្ត្រអន្តរជាតិ និងតំបន់។ *សូមមើល ឧទាហរណ៍៖* គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី *Toonen តទល់នឹងប្រទេសអូស្ត្រាលី* លេខ 488/92 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៥.១, រឿងក្តី *Norris តទល់នឹង ប្រទេស អៀរឡង់* លេខ 10581/83 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៨៨ កថាខណ្ឌ ២៩, ៣២-៣៤ និងរឿងក្តី IACHR, *Suarez Rosero តទល់នឹងប្រទេសអេក្វាឌ័រ* ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៩៨។

សម្ហូហភាពដែលបានបង្កឡើងមកលើសង្គមទាំងមូល ឬក៏សំដៅលើផ្នែកផ្សេងៗនៅក្នុងសង្គម មិនមែនពាក់ព័ន្ធតែបុគ្គល[48]តែមួយមុខប៉ុណ្ណោះទេ។

៣៣. ដូច្នេះ ឧក្រិដ្ឋកម្មទ្រង់ទ្រាយធំដែលបានប្រព្រឹត្តលើក្រុម ឬប្រជាជនមួយផ្នែកធំ ជាលក្ខណៈឧក្រិដ្ឋកម្មទូលំទូលាយ ក៏អាចប៉ះពាល់ផងដែរដល់ជនជាតិផ្សេងទៀតនៅក្នុងប្រទេសដូចគ្នាតែមួយទោះបីជាជនជាតិទាំងនោះមានវត្តមាន ឬគ្មានវត្តមាននៅពេលនោះក៏ដោយ។ ឧក្រិដ្ឋកម្មប្រភេទនេះ អាចប៉ះពាល់រហូតដល់អ្នកដែលកើតក្រោយព្រឹត្តិការណ៍ទាំងនោះ ដូចជា ប៉ះពាល់ដោយសារបានដឹងរឿងរ៉ាវតាមការនិទានប្រាប់របស់ជនរងគ្រោះផ្ទាល់ ឬជនរងគ្រោះមិនផ្ទាល់[49]។

៣៤. ដូច្នេះ ព្យសនកម្មខាងផ្លូវចិត្ត គឺរួមបញ្ចូលទាំងព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់ទទួលរងដោយផ្ទាល់ពីឧក្រិដ្ឋកម្ម ឬជាព្យសនកម្មដែលជនរងគ្រោះមិនផ្ទាល់ បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់ ឬដោយសារព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួលរង។ ជនរងគ្រោះមិនផ្ទាល់ អាចទទួលរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឱ្យតែពួកគាត់ជាសមាជិកនៅក្រុមគោលដៅតែមួយ ឬក្នុងសហគមន៍តែមួយ ឬ ប្រសិនបើជនរងគ្រោះមិនផ្ទាល់ បានទទួលរងព្យសនកម្មដោយសារតែជនរងគ្រោះផ្ទាល់បានទទួលរង។

---

[48] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៦៨។

[49] សូមមើល រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Katanga* សេចក្តីសម្រេចលើបញ្ហាពន្យសកម្មឆ្លងជំនាន់ដែលអ្នកដាក់ពាក្យសុំខ្លះបានអះអាងដើម្បីទាមទារសំណងដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងវិញនៅក្នុងសាលដីកាចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង II តុលាការ ICC (ICC-01/04-01/07) កថាខណ្ឌ ១០។ យើង Michael Bohlander កត់សម្គាល់ថា ដោយសារក្របខណ្ឌពេលវេលាខុសគ្នានៃការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ជាពិសេសនៅដំណាក់កាលស៊ើបសួរ ទើបមិនទាន់ចាំបាច់ត្រូវធ្វើការកំណត់ឱ្យតឹងរឹងបែបនេះទេអំពីចំនួនជនរងគ្រោះ។ នីតិវិធីដ៏ត្រឹមត្រូវសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាអំពីបញ្ហានេះឱ្យកាន់តែលម្អិត គឺនៅដំណាក់ជំនុំជម្រះក្តី។

**ង) អត្ថិភាពនៃទំនាក់ទំនងហេតុផល**

៣៥. វិធានផ្ទៃក្នុង ២៣ *ស្ទួន*(១)(ខ) ដោយស្របតាមបទដ្ឋានអន្តរជាតិ[50] តម្រូវឱ្យមានអត្ថិភាពនៃទំនាក់ទំនងហេតុផលរវាងព្យសនកម្មដែលទទួលរង ជាមួយនឹងឧក្រិដ្ឋកម្មយ៉ាងហោចណាស់ចំនួនមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទលើជនត្រូវចោទ។

៣៦. អ.ប.ជ ដោយបានពិចារណាលើលក្ខណៈនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានបកស្រាយក្នុងន័យទូលាយអំពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផល ហើយបានអនុញ្ញាតឱ្យទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលការចោទប្រកាន់អំពីព្យសនកម្មរបស់ពួកគាត់ មិនចាំបាច់ទាល់តែកើតឡើងពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅទីតាំងដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬនៅក្នុងដីកាដំណោះស្រាយនោះទេ។ ជាពិសេស អ.ប.ជ បានពិចារណាលើលក្ខណៈទូលាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់ និងវិសាលភាពនៃសហឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០២[51]។

**ច) ភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

៣៧. ផ្អែកលើដីកាដំណោះស្រាយលើ **យឹម ទិត្យ** អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅភូមិភាគពាយ័ព្យ ពីដើមឆ្នាំ ១៩៧៧ ឬពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផល ប្រសិនបើមានលក្ខខណ្ឌចំនួនពីរ។

---

[50] *សូមមើល៖* រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Lubanga* សាលដីកាស្តីពីសំណើរបស់ព្រះរាជអាជ្ញា និងមេធាវីការពារក្តីស្នើសុំពន្យារពេលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង I ស្តីពីការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC (ICC-01/04-01/06-1347) កថាខណ្ឌ ១៨។ សេចក្តីសម្រេចរឿងក្តី *Kony* កថាខណ្ឌ ៣៦, ៣៨។

[51] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៤៩, ៦៦, ៦៨, ៦៩-៧២, ៧៧។

ក. ទីមួយ ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង បណ្តាលមកពីការអនុវត្តគោលនយោបាយដែលត្រូវបានចោទប្រកាន់ដូចខាងក្រោម នៅទីតាំងណាមួយនៅភូមិភាគពាយ័ព្យ៖

i. ការបង្កើត និងដំណើការសហករណ៍ និងការដ្ឋាន ដែលបានអនុវត្តតាមរយៈការធ្វើឲ្យប្រជាជនក្លាយជាទាសករ។

ii. ការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ ដែលបានអនុវត្ត *ជាអាទិ៍* តាមរយៈការរៀបអាពាហ៍ពិពាហ៍ឲ្យអ្នករស់នៅភូមិភាគពាយ័ព្យដោយបង្ខំ។

iii. ការកសាង"សមាសភាពមិនល្អ" តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ពលកម្មដោយបង្ខំ និងការដាក់ឲ្យស្ថិតក្នុងស្ថានភាពអមនុស្សធម៌ ឬការសម្លាប់"ខ្មាំង" និង "សមាសភាពមិនល្អ"ទាំងក្នុងជួរ ប.ក.ក ទាំងនៅក្រៅជួរ ប.ក.ក។

iv. ការដាក់គោលដៅលើក្រុមជាក់លាក់។

ខ. ទីពីរ តាមការចោទប្រកាន់ ការអនុវត្តគោលនយោបាយទាំងនេះអាចជា៖

i. អំពើប្រល័យពូជសាសន៍ដែលមានចែងក្នុងមាត្រា៤នៃច្បាប់អ.វ.ត.ក

ii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬ

iii. ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក

iv. ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ **យឹម ទិត្យ**។

៣៨. អ្នកដាក់ពាក្យសុំបីប្រភេទបន្ថែមទៀត ក៏បំពេញតាមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផលនេះដែរ។

ក. ប្រភេទទី ១ គឺអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារផែនការរួមទូទាំងប្រទេសដែលបានដាក់ជាបទចោទ អនុវត្តយ៉ាងហោចណាស់ពីឆ្នាំ

១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលុបបំបាត់ខ្មែរក្រោមទាំងស្រុង ឬមួយផ្នែក។ អ្នកដាក់ពាក្យសុំប្រភេទនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផលប្រសិនបើភស្តុតាងបង្ហាញថា ពួកគាត់គឺជាជនរងគ្រោះដោយសារ៖

i. អំពើប្រល័យពូជសាសន៍ដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក
ii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬ
iii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក
iv. ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក
v. ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ **យឹម ទិត្យ**[52]។

ខ. ទីពីរ គឺអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មខាងក្រោមនេះដែលបានត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុយ៉ាងហោចណាស់រវាងខែកញ្ញា-តុលាឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ អ្នកដាក់ពាក្យសុំប្រភេទនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផលប្រសិនបើភស្តុតាងបង្ហាញថា ពួកគាត់គឺជាជនរងគ្រោះដោយសារ៖

i. អំពើប្រល័យពូជសាសន៍ដែលមានចែងក្នុងមាត្រា៤នៃច្បាប់អ.វ.ត.ក
ii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬ
iii. ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក
iv. ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ **យឹម ទិត្យ**[53]។

---

[52] **D281** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ* ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៥ KH ERN 01178416។

[53] **D281** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ* ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ KH ERN 01178402។

គ. ចុងក្រោយ គឺអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មខាងក្រោមនេះដែលត្រូវបានចោទនៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីកន្លែងសម្លាប់មនុស្សភូមិព្រៃល ទីកន្លែងសម្លាប់មនុស្សវត្តអង្គញ្ញដី ទីកន្លែងសម្លាប់មនុស្សភូមិព្រៃស្លែង ឬព្រៃសុខុន និងទីកន្លែងសម្លាប់មនុស្សវត្តអង្គសិរីមុនី៖

i. អំពើប្រល័យពូជសាសន៍ដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក

ii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬ

iii. ឧក្រិដ្ឋកម្មមួយ ឬលើសពីមួយក្នុងចំណោមអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក

iv. ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មថ្នាក់ជាតិដែលមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក

v. ហើយឧក្រិដ្ឋកម្មបែបនោះអាចកើតឡើងដោយសារ **យឹម ទិត្យ**[54]។

៣៩. អង្គហេតុដែលបានដកចេញយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន[55] ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានចោទនោះ អាចនៅតែជាមូលដ្ឋាននៃដីកាសម្រេចលើភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើបានបំពេញតាមលក្ខខណ្ឌខាងលើ និងខាងក្រោមនេះ។

## ឆ) បទដ្ឋានភ័ស្តុតាង និង ភាពគ្រប់គ្រាន់នៃព័ត៌មាន

៤០. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអាចឱ្យផ្ទៀងផ្ទាត់បានថា ពាក្យសុំទាំងនោះត្រូវតាមការកំណត់នៃវិធានផ្ទៃក្នុង[56]។ ស.ច.ស ត្រូវ

---

[54] **D281** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ* ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ KH ERN 01178402។

[55] **D359** *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[56] វិធាន ២៣ ស្ទួន(៤) វិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.៥។

ជឿថា អង្គហេតុដែលរងការចោទប្រកាន់ គឺទំនងជាពិត ជាជាងមិនពិត ដើម្បីបញ្ជាក់ពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[57]។ ជាពិសេស ទម្រង់ព័ត៌មានជនរងគ្រោះ និងចម្លើយរបស់អ្នកដាក់ពាក្យសុំ ត្រូវតែមានភាពលម្អិត និងយថាភាពក្នុងកម្រិតមួយចាំបាច់ ដែលអាចឲ្យជឿទុកចិត្តបាននៅក្នុងកាលៈទេសៈនៃសំណុំរឿងនេះ[58]។ ទម្រង់ព័ត៌មានជនរងគ្រោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវតែបំពេញឲ្យបានគ្រប់គ្រាន់ និងមានលក្ខណៈស៊ីសង្វាក់គ្នាជាទូទៅ[59]។ ដូច្នេះ យើង Michael Bohlander អនុវត្តបទដ្ឋានភវនីយភាពក្នុងការវាយតម្លៃលើការអះអាងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងការវាយតម្លៃចម្លើយរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបញ្ជាក់ពីការអះអាងរបស់ពួកគាត់ យើង Michael Bohlander ផ្តល់ទំនុកចិត្តច្រើនលើចម្លើយបែបនេះ ដោយពិនិត្យឃើញថា ជនរងគ្រោះពុំមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាលក្ខណៈបុគ្គលតាមរយៈការដាក់បណ្តឹងរដ្ឋប្បវេណី ទេ[60]។

៤១. ដោយសារលក្ខណៈពិសេសនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អ.វ.ត.ក. និងកាលៈទេសៈនៃសំណុំរឿងនេះ ទើបភស្តុតាងដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចពឹងផ្អែកបាន គឺមានកម្រិតតិចតួចដោយសារកត្តាផ្សេងៗដូចខាងក្រោម៖

ក) ពេលវេលាកន្លងផុតទៅយូរ និងផលប៉ះពាល់ដែលបញ្ហានេះអាចមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំ ក្នុងការផ្តល់ឯកសារភស្តុតាងពាក់ព័ន្ធនឹងព្យសនកម្មដែលខ្លួនទទួលរង ដូចជា ឯកសារពេទ្យក្នុងករណីដែលមានការចោទប្រកាន់អំពីព្យសនកម្មខាងរាងកាយ[61]។

---

[57] វិធាន ២៣ ស្ទួន(១) វិធានផ្ទៃក្នុង។

[58] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៥៣៦។ សេចក្តីសម្រេចរឿងក្តី *Kony* កថាខណ្ឌ ៣៥-៣៦, ៣៨។

[59] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៥៣៦។

[60] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៥៣៦។

[61] សាលដីកាដែលទទួលបានសម្លេងភាគច្រើនមិនបានដោះស្រាយបញ្ហាទាំងនេះ ប៉ុន្តែ យើង Michael Bohlander យល់ឃើញ ថា មតិយោបល់ដោយឡែករបស់ចៅក្រម Marchi-Uhel ស្តីពីចំណុចនេះ មានភាពពាក់ព័ន្ធ និងមានប្រយោជន៍៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ *យោបល់ជំទាស់ដោយឡែក និងមួយផ្នែករបស់លោកស្រីចៅក្រម Catherine Marchi-Uhel* កថាខណ្ឌ ៦៦។

ខ) ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានបញ្ហាសមត្ថភាពក្នុងការបង្ហាញ ក្នុងការឆ្លើយតប ឬធ្វើកំណត់ហេតុឱ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីផលប៉ះពាល់ដែលស្ថានភាពនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានមកលើសុខភាពផ្លូវចិត្តរបស់ប្រជាជន។

គ) ការជម្លៀស ការប្តូរទីកន្លែង និង ការផ្លាស់ទីលំនៅរបស់ប្រជាជនទៅតាមតំបន់ផ្សេងៗ និងផលប៉ះពាល់ដែលបញ្ហានេះមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តល់ភ័ស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ទ្រព្យសម្បត្តិ និងលទ្ធភាពក្នុងការផ្តល់ភ័ស្តុតាងបញ្ជាក់អំពីប្រាក់ចំណូលក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ប្រាក់ចំណូល។

៤២. កត្តាទាំងនេះកាត់បន្ថយកម្រិតនៃលក្ខខណ្ឌតម្រូវសម្រាប់ភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្ម។

i. <u>ភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្មជាប្រាក់កាស</u>

៤៣. តុលាការសិទ្ធិមនុស្សថ្នាក់តំបន់ បង្កើតបទដ្ឋានខ្ពស់សម្រាប់ភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្មផ្នែកប្រាក់កាស[62] ប៉ុន្តែ តុលាការទាំងនេះ ផ្តល់របៀបវាយតម្លៃផ្សេងទៀតដើម្បីវាយតម្លៃលើព្យសនកម្មប្រភេទនេះក្នុងករណីដែលជនរងគ្រោះមិនអាចរកភ័ស្តុតាងបានដើម្បីបញ្ជាក់ពីការអះអាងអំពីព្យសនកម្មផ្នែកប្រាក់កាស[63]។ តុលាការទាំងនេះអនុវត្តបទដ្ឋានកាន់តែតឹងរឹង ដោយសារថាតុលាការផ្តល់សំណងជាប្រាក់ដល់បុគ្គលម្នាក់ៗ។ ប៉ុន្តែ អ.វ.ត.កមិនផ្តល់សំណងប្រភេទនេះទេ។

---

[62] ឧទាហរណ៍៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប សេចក្តីណែនាំអនុវត្តចេញដោយប្រធានតុលាការ អនុលោមតាមវិធាន ៣២ នៃវិធានតុលាការ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧ មាត្រា ១១៖ "*អ្នកដាក់ពាក្យសុំ ត្រូវបង្ហាញថា ព្យសនកម្មខាងប្រាក់កាស បានកើតឡើងដោយសារការរំលោភបំពានណាមួយ ឬការរំលោភបំពានជាច្រើនដែលរងការចោទប្រកាន់។ អ្នកដាក់ពាក្យសុំ ត្រូវដាក់ឯកសារពាក់ព័ន្ធដើម្បីបញ្ជាក់ភ័ស្តុតាងតាមដែលអាចធ្វើបាន មិនមែនបញ្ជាក់តែអត្ថិភាពនៃព្យសនកម្មប៉ុណ្ណោះទេ ប៉ុន្តែត្រូវបញ្ជាក់ទំហំ និងតម្លៃព្យសនកម្មនោះផង*"។

[63] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី*Ipek តទល់នឹងប្រទេសទួរគី* លេខ 25760/94 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ២២៧។ *សូមមើលផងដែរ៖* រឿងក្តី *Akdivar និងអ្នកផ្សេងទៀត តទល់នឹងប្រទេសទួរគី* លេខ 99/1995/605/693 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៦-១៩។ គណៈកម្មការអន្តរអាមេរិចស្តីពីសិទ្ធិមនុស្ស

៤៤. តាមសំអាងហេតុខាងលើ និងដោយសារថា អ.វ.ត.ក ផ្តល់តែសំណងសមូហភាព និង សំណងផ្លូវចិត្ត[64] ទើបជាការសមស្របត្រូវប្រកាន់យកវិធីសាស្ត្របន្ធូរបន្ថយនៅពេលដែលពិចារណាលើព្យសនកម្មខាងប្រាក់កាសដែលអ្នកដាក់ពាក្យសុំអះអាងថាបានទទួលរង ចំពោះសេចក្តីសម្រេចលើភាពអាចទទួលយកព្យសនកម្មបែបនេះ។

ii.ភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្មមិនមែនជាប្រាក់កាស

៤៥. អ.ជ.ត.ក បានឯកភាពតាមការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា មានចំណងនៃក្តីស្រលាញ់ និងការរស់នៅក្នុងបន្ទុករវាងជនរងគ្រោះផ្ទាល់ជាមួយនឹងសមាជិកគ្រួសារដែលជិតបំផុត[65]។ ក្នុងបរិបទប្រទេសកម្ពុជា ដោយសារបរិបទពិសេសនៃភាពជិតស្និទ្ធគ្នា និងការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងសមាជិកគ្រួសារច្រើន[66] ព្រមទាំងការរៀបចំរចនាសម្ព័ន្ធសង្គមឡើងវិញនៅសម័យកម្ពុជាប្រជាធិបតេយ្យ[67] និងការលំបាកជាក់ស្តែងក្នុងការទទួលបានភ័ស្តុតាងបញ្ជាក់អំពីសម្ព័ន្ធភាពគ្រួសារ ទើបការសន្និដ្ឋាននេះត្រូវយកមកអនុវត្តរហូតដល់សមាជិកគ្រួសារដែលមិនជិតបំផុត ដើម្បីអនុវត្តវិធីសាស្ត្រដែលមានលក្ខណៈបត់បែនពាក់ព័ន្ធនឹងភ័ស្តុតាងបញ្ជាក់អំពីសម្ព័ន្ធភាពគ្រួសារ។

៤៦. យើង Michael Bohlander បានសម្រេចអនុវត្តវិធីសាស្ត្រដែលមានលក្ខណៈទូលាយសម្រាប់ព្យសនកម្មដែលមិនមែនជាប្រាក់កាស។ នៅក្នុងសំណុំរឿងនេះ លក្ខណៈ វិសាលភាព និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ និងបទចោទ គឺដល់កម្រិតដែលអាចឱ្យមានការ

---

រឿងក្តី *Caracazo តទល់នឹងប្រទេសវេណេហ្ស៊ុយអេឡា* ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២ (សំណង និងការចំណាយ) កថាខណ្ឌ ៥០(ខ), (ឃ)។ **សំណុំរឿងលេខ 001-F13.1.37** *សំអាងហេតុ ៣៧៖ សំណង "សំណងសមូហភាព៖ ទ្រឹស្តី និង គោលការណ៍"* ដាក់នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ EN ERN 00620529។

[64] វិធាន ២៣ *ស្ទួនបួន*។

[65] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤៤៨។

[66] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ៦៤៣។ **សំណុំរឿង ០០១-E1/68.1** *ប្រតិចារឹកសវនាការ – "ឌុច" សវនាការ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ ("សក្ខីកម្មអ្នកជំនាញ") KH ERN 00371592 បន្ទាត់ទី ១៤-១៨, KH ERN 00371600 ទំព័រទី ២២-២៥, KH ERN 00371601 បន្ទាត់ទី១-៧។ សូមកត់សម្គាល់ថា តាមសំណៅជាភាសាបារាំង និងខ្មែរ សំណៅជាភាសាអង់គ្លេស ត្រង់ ERN 00370988 បន្ទាត់ទី ២៤ គួរដាក់ពាក្យថា "together-ជាមួយគ្នា" មិនមែនពាក្យ "separately-ដោយឡែកពីគ្នា"។

[67] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៧០, ៨០។

សន្និដ្ឋានថាផលប៉ះពាល់ខាងផ្លូវចិត្តមកលើជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនេះគឺមានកម្រិតធ្ងន់។ ការសន្និដ្ឋានបែបនេះស្របតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សថ្នាក់តំបន់[68]។

iii. ភស្តុតាងបញ្ជាក់អត្តសញ្ញាណ

៤៧. រាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានព័ត៌មានលម្អិត ដើម្បីអាចឲ្យផ្ទៀងផ្ទាត់បានថា អ្នកដាក់ពាក្យសុំគឺជាជនរងគ្រោះ[69]។ ចំពោះប្រការនេះ ក.ស.ច.ស បានពិនិត្យស្នាមក្រយៅដៃ និងឯកសារបញ្ជាក់អត្តសញ្ញាណដែលមាននៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះនីមួយៗ និងឯកសារដែលភ្ជាប់មកជាមួយ ឬដែលបានបន្ថែមមកជាមួយ។

៤៨. ប៉ុន្តែ យើង Michael Bohlander ទទួលយកតាមការសម្រេចរបស់ អ.ប.ជ ដែលថា "*ឯកសារដែលចេញជាទម្រង់ ឬឯកសារផ្សេងទៀតពីចាស់ទុំក្នុងភូមិ ឬ មេភូមិ*"[70] គឺជាព័ត៌មានគ្រប់គ្រាន់ហើយក្នុងការបញ្ជាក់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យើង Michael Bohlander ក៏ទទួលស្គាល់ថា ក្នុងករណីគ្មានអត្តសញ្ញាណប័ណ្ណ ឬ គ្មានស្នាមក្រយៅដៃ គឺជាព័ត៌មានគ្រប់គ្រាន់ហើយប្រសិនបើអ្នកដាក់ពាក្យសុំអាចត្រូវស្គាល់អត្តសញ្ញាណបានតាមរយៈព័ត៌មានដែលមាននៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ។

## III. អំពីសំណើចុងក្រោយដែលស្នើសុំវិធានការការពារ

៤៩. អ្នកដាក់ពាក្យសុំដែលស្នើសុំវិធានការការពារ រស់នៅសហរដ្ឋអាមេរិក។ នៅក្នុងសំណើសុំវិធានការការពារដែលមាននៅក្នុងពាក្យសុំរបស់គាត់ គាត់បានបញ្ជាក់ថា គាត់ខ្លាចថា "*រដ្ឋាបាលភិបាលបច្ចុប្បន្ននេះនឹងមករក[គាត់]*" ប៉ុន្តែ មិនបានបញ្ជាក់ពីប្រភេទវិធានការការពារដែលគាត់ស្នើសុំនោះទេ[71]។ អ្នកដាក់ពាក្យសុំដែលស្នើសុំវិធានការការពារ មិនបានផ្តល់សំអាង

---

[68] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Peck តទល់នឹង ចក្រភពអង់គ្លេស* លេខ 44647/98 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៨។ គណៈកម្មាធិការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស រឿងក្តី *Ituango Massacres តទល់នឹង ប្រទេសកូឡុំប៊ី* ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៨៤, រឿងក្តី *Caracazo តទល់នឹងប្រទេសវេណេហ្ស៊ុយអេឡា* ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២ កថាខណ្ឌ ៥០(ង)។

[69] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.៥(ក)។

[70] សាលដីកាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២ កថាខណ្ឌ ៩៥។

[71] **D5/2008** *ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុន ឈីវហុង* ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ EN ERN 01480116។

ហេតុដែលគាត់ខ្លាចរដ្ឋាភិបាលបច្ចុប្បន្ននេះទេ។ ហេតុនេះ សំណើនេះមិនច្បាស់លាស់ដែលតម្រូវឱ្យមានវិធានការការពារទេ។

**តាមសំអាងហេតុខាងលើ យើង Michael Bohlander៖**

៥០. **ប្រកាស** ថា រាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ទាំងអស់ ត្រូវបានទទួលស្គាល់។

៥១. **ប្រកាស** ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ខ មិនត្រូវបានទទួលស្គាល់ឡើយ។

៥២. **ប្រកាស** ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារដែលពាក់ព័ន្ធ ដូចមានបង្ហាញនៅឧបសម្ព័ន្ធ គ ត្រូវចាត់ទុកថាជាពាក្យបណ្តឹង។

៥៣. **បដិសេធ**សំណើសុំវិធានការការពារដែលស្នើឡើងដោយអ្នកដាក់ពាក្យសុំស្នើសុំវិធានការការពារ។

ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស និង ភាសាខ្មែរ ដោយសំណៅបកប្រែនៃឧបសម្ព័ន្ធជាភាសាខ្មែរនឹងដាក់តាមក្រោយ។

ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co-Investigating Judge
Co-juge d'instruction international